ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: .....187..... PEAC.អក

រាជធានីភ្នំពេញ, ថ្ងៃទី 01 ខែ 02 ឆ្នាំ 2017

# សេចក្តីជូនដំណឹង
## ស្តីពី

ការអញ្ជើញចូលរួមដេញថ្លៃ ការងារជួសជុលគ្រឹះបង្គោលលេខ 130 និងបង្គោលលេខ 131 ខ្សែបញ្ជូន 230kV ពីអនុស្ថានីយ៍តាកែវ ទៅព្រំដែនវៀតណាម ដែលពុកផុយបេតុង ជូននាយកដ្ឋានបញ្ជូនអគ្គិសនី

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការងារជួសជុលគ្រឹះបង្គោលលេខ 130 និងបង្គោលលេខ 131 ខ្សែបញ្ជូន 230kV ពីអនុស្ថានីយ៍តាកែវ ទៅព្រំដែនវៀតណាម ដែលពុកផុយបេតុង ជូននាយកដ្ឋានបញ្ជូនអគ្គិសនី ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី 01 ខែ កុម្ភៈ ឆ្នាំ 2017 តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី 01 ខែ មីនា ឆ្នាំ 2017 វេលាម៉ោង 14:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង 15:30 ថ្ងៃទី 01 ខែ មីនា ឆ្នាំ 2017 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ